24-02-97
(23)

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

ព្រះរាជក្រម នស/រកម/០២៩៧/០៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧត្តគោសុជាត ឥសុធិវង្ស អគ្គមហាមុរសរតនៈ នរោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស-៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស រកត ១០៩៤ ៩០ ចុះថ្ងៃទី៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣
- បានឃើញព្រះរាជក្រមលេខ១១ នស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ ជស-រកម- ០៩៩៥ ០១ ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការកែ តម្រូវច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកនីតិសម្បទា និងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៧ ទាសម័យប្រជុំលើកទី៧ នីតិកាលទី១ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

ច្បាប់
ស្តីពី
ការទូទាត់ថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥

ជំពូកទី១
បទប្បញ្ញត្តិទូទៅ

មាត្រា១ – ត្រូវបានយល់ព្រមតាមការអនុវត្តនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស-៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីការកែសំរួល នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៩៩៥/០១ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ ១៩៩៥ ។ ការអនុវត្តនេះលេចចេញជាលទ្ធផលដូចខាងក្រោម ៖

កិច្ចប្រតិបត្តិការចំណូល និងចំណាយនៃការគ្រប់គ្រង ឆ្នាំ ១៩៩៥ (១)	ច្បាប់ហិរញ្ញវត្ថុ ដើម ឆ្នាំ១៩៩៥	ច្បាប់ហិរញ្ញវត្ថុ កែសំរួល	ច្បាប់ទូទាត់ ថវិកា
សរុបចំណូល	១.០៥៨.៦០០	១.២៨៣.០០០	១.២៨៣.៧៩៥
សរុបចំណាយ	១.០៥៨.៦០០	១.២៨៣.០០០	១.២៨៩.៤១៦

ចំនួនលើសនៃគណនេយ្យចំណាយ/ចំណូល	-	-	៤៥.៦២១
កិច្ចប្រតិបត្តិការនៃច្បាប់ស្តីពីហិរញ្ញវត្ថុដែលអនុវត្តចានដោយរតនាគារជាតិ			
ចំណូលថវិកា	៧០៩.២០០	៩១០.៩០០	៧២៣.៣៨៥
* ចំណូលក្នុងប្រទេសជាប្រចាំ	៥៨១.១០០	៦៩៤.០០០	៦៣៥.៣១៥
* ចំណូលក្នុងប្រទេសជាមូលធន	១២.០០០	១២.៣៨០	៧.៦៦៤
+ ចំណូលក្រៅប្រទេសជាមូលធន	១១៦.១០០	២០៤.៥២០	៨០.៤០៦
ចំណាយថវិកា	៧០៩.២០០	៩១០.៩០០	៧៦៩.០០៦
+ ចំណាយជាប្រចាំ	៦៥២.៧០០	៧៩២.២០០	៦៩២.៣៥៤
+ ចំណាយជាមូលធន	៥៦.៥០០	១១៨.៧០០	៧៦.៦៥៣
កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋដែលអនុវត្តចានក្រៅ រតនាគារជាតិ			
ចំណូលថវិកា			៦៦.១៩១
* ចំណូលក្នុងប្រទេសជាប្រចាំ			
+ ចំណូលក្នុងប្រទេសជាមូលធន			
+ ចំណូលក្រៅប្រទេសជាមូលធន			៦៦.១៩១
ចំណាយថវិកា			៦៦.១៩១
+ ចំណាយជាប្រចាំ			៣៩.៣៩១
+ ចំណាយជាមូលធន			២៦.៨០០
វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ដែលចានអនុវត្តក្រៅរតនាគារជាតិ			
- ធនធានជាមូលធនសំរាប់តំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	៣៨៩.៤០០	៣៧២.១០០	៤៥៤.២១៩
-ចំណាយជាមូលធនដោយធនធានសំរាប់តំរោងដោយហិរញ្ញប្បទានក្រៅប្រទេស	៣៨៩.៤០០	៣៧២.១០០	៤៥៤.២១៩

(១)សរុបកិច្ចប្រតិបត្តិការចំណូល ចំណាយដែលចានលើកឡើងនេះ មានលក្ខណៈចង្អុលបង្ហាញតែប៉ុណ្ណោះ ពីព្រោះកិច្ចប្រតិបត្តិការនេះ ត្រូវចានអនុវត្តផ្ទាល់ដោយហិរញ្ញប្បទានក្រៅប្រទេសមិនឆ្លងកាត់រតនាគារជាតិ និងមិនចានចុះកិច្ចបញ្ជីកាក្នុងគណនេយ្យរតនាគារជាតិទេ ។

កិច្ចប្រតិបត្តិការនេះគ្រាន់តែជាកម្មវត្ថុនៃការប៉ាន់ប្រមាណតួលេខមួយ ក្រោយពីមានការពិគ្រោះព្រមព្រៀងគ្នាជាមួយអ្នកផ្តល់មូលនិធិ ។ ចំណែកឯចំណាយមួយភាគរបស់ក្រសួងការពារជាតិ និងរដ្ឋបាលស៊ីវិល ក៏មិនបានចុះកិច្ចបញ្ជីការនៅក្នុងគណនេយ្យរតនាគារជាតិដែរ ហើយការចំណាយនេះ ត្រូវបានផ្តល់ហិរញ្ញប្បទានដោយការខ្វីពីផ្នែកឯកជនខាងក្រៅ និងក្នុងប្រទេស ព្រមទាំងដោយប្រភពធនធានជាតិដែលបានកំណត់ ។

មាត្រា២ .– ចំណូលលំអិតតាមមាតិកាថវិកាត្រូវបានបញ្ជាក់នៅតារាង « ក » ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

ចំណាយលំអិតតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល និងតាមជំពូកត្រូវបានបញ្ជាក់នៅតារាង «ខ» ដូចមានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង «ខ១» ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៥ ទីនឹងត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែល ។

ការប៉ាន់ប្រមាណសំរេចបានស្តីពីវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ចំពោះចំណូលត្រូវបានលំអិតតាមមាតិកាថវិកា . និងចំពោះចំណាយត្រូវបានលំអិតតាមក្រសួង និង ស្ថាប័នសាធារណៈប្រហាក់ប្រហែល ហើយត្រូវបានបញ្ជាក់ជាបន្តបន្ទាប់នៅតារាង« ក » និង «ខ »ដូច មានភ្ជាប់មកជាមួយច្បាប់នេះ ។

តារាង « ខ២ » ដែលភ្ជាប់មកជាមួយច្បាប់នេះ គឺជាបញ្ជីនៃគំរោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសក្រៅរតនាគារជាតិ ដែលសំរេចបានក្នុងរយៈពេលនៃការគ្រប់គ្រងឆ្នាំ ១៩៩៥ និងត្រូវបានបែងចែកតាមក្រសួង និងស្ថាប័នសាធារណៈប្រហាក់ប្រហែលដោយអ្នកផ្តល់បរទេស ។

ជំពូកទី២

បទប្បញ្ញត្តិ ស្តីពីកិច្ចប្រតិបត្តិការថវិកា

មាត្រា ៣ .– ការប្រមូលចំណូល ជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋពីពន្ធដារ វិភាគទាន អាករ ផលិតផល និងផលទុន ព្រមទាំងការធ្វើអោយសំរេចនូវអំណោយ មូលនិធិ

បដិភាគ និងធនធានបានមកពីការខ្ចី ដែលបានអនុញ្ញាតគ្រោងទុកនៅក្នុងច្បាប់ស្តីពីការកែតំរូវ
នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

មានចំនួនទឹកប្រាក់សរុប :	:	៩១០.៩០០ លានរៀល
-ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់	:	៧២៣.៣៨៥ លានរៀល
-ដូច្នេះមានចំណូលខ្វះចំនួន	:	១៨៧.៥១៥ លានរៀ
ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷		
-ចំណូលក្នុងប្រទេសជាប្រចាំ - តំរោងកែតំរូវ	:	៦៩៤.០០០ លានរៀល
_ការសំរេចបាន	:	៦៣៥.៣១៥ លានរៀល
_មានចំនួនខ្វះ	:	៥៨.៦៨៥ លានរៀល
-ចំណូលក្នុងប្រទេសជាមូលធន _ តំរោងកែតំរូវ	:	១២.៣៨០ លានរៀល
_ការសំរេចបាន	:	៧.៦៦៤ លានរៀល
_មានចំនួនខ្វះ	:	៤.៧១៦ លានរៀល
-ចំណូលក្រៅប្រទេសជាមូលធន_តំរោងកែតំរូវ	:	២០៤.៥២០ លានរៀល
_ការសំរេចបាន	:	៨០.៤០៦ លានរៀល
_មានចំនួនខ្វះ	:	១២៤.១១៤ លានរៀល

មាត្រា ៤ .-ចំណាយថវិកាទូទៅរបស់រដ្ឋ ដែលត្រូវទទួលការអនុញ្ញាតតាមច្បាប់
ស្តីពីការកែតំរូវនៃច្បាប់ ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

មានចំនួនទឹកប្រាក់សរុប	:	៩១០.៩០០ លានរៀល
-ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់	:	៧៦៩.០០៦ លានរៀល
-ដូច្នេះមានការសន្សំសំចៃឥណទាន ចំនួន	:	១៤១.៨៩៤ លានរៀល
ដែលជាលទ្ធផលនៃការវិវត្តដូចតទៅ ÷		
-ចំណាយជាប្រចាំ - តំរោងកែតំរូវ	:	៧៩២.២០០ លានរៀល
_ការសំរេចបាន	:	៦៩២.៣៥៣លានរៀល
_មានការសន្សំសំចៃ ចំនួន	:	៩៩.៨៤៧ លានរៀល
-ចំណាយជាមូលធន - តំរោងកែតំរូវ	:	១១៨.៧០០ លានរៀល

_ការសំរេចចាន : ៧៦.៦៥ លានរៀល

_មានចំនួនខ្វះ : ៤៦.០៤៧ លានរៀល

មាត្រា ៥ .- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស និងលទានត្រោង ចំណាយនៅក្នុងច្បាប់ ស្តីពីការកែសំរួលនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ មានចំនួន ទឹកប្រាក់សរុប : ៦៦.៤០០ លានរៀល

-ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់ : ៥៦.៤៦៣ លានរៀល

-ដូច្នេះមានចំនួនខ្វះ : ៩.៥៣៧ លានរៀល

មាត្រា ៦ .- ការអនុវត្តកិច្ចប្រតិបត្តិការចំណូល [illegible] តាមច្បាប់ស្តីពីការកែសំរួលនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលសំរេចបានដោយរតនាគារជាតិ ដូចមានបញ្ជាក់នៅក្នុងមាត្រា ៣ និង មាត្រា៤ខាងលើបានបង្ហាញជាលទ្ធផលនូវចំណេះលើសចំណូលដូចតទៅ ÷

- ចំណូលថវិកាដែលសំរេចបានដោយរតនាគារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ : ៧២៣.៣៨៥ លានរៀល

_ចំណាយថវិកាដែលសំរេចបានដោយរតនាគារជាតិ

សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ : : ៧៦៩.០០៦ លានរៀល

_ចំនួនលើសនៃ គណនេយ្យចំណាយលើចំណូល : ៤៥.៦២១លានរៀល

ដោយអនុលោមទៅតាមបទប្បញ្ញត្តិក្នុងមាត្រា៥៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ចំនួនលើសនៃគណនេយ្យចំណាយលើចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ មានចំនួនទឹកប្រាក់ ៤៥.៦២១ លានរៀល ត្រូវបានកត់ត្រានៅគណនីលទ្ធផល ដែលបានបើកនៅក្នុងគណនេយ្យរតនាគារជាតិ ។

ជំពូកទី៣

បទប្បញ្ញត្តិស្តីពីកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ដែលបានអនុវត្តក្រៅរតនាគារជាតិ

មាត្រា៧.- ត្រូវបានយល់ព្រមតាមការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋក្រៅរតនាគារជាតិ នូវចំណូលដែលសំរេចបាន និងចំណាយដែលបានអនុវត្តលើសពីការអនុញ្ញាតថវិកាទូទៅរបស់រដ្ឋ មានចំនួនទឹកប្រាក់ដូចខាងក្រោមនេះ ÷

សរុបចំណូល	:	៦៦.១៩១ លានរៀល
• ចំណូលក្រៅប្រទេសជាមូលធន	:	៦៦.១៩១ លានរៀល
• អំណោយពិសេសសំរាប់រំលស់បំណុល	:	២៦.៨០០ លានរៀល
• ធនធាននៃការខ្ចីពីបរទេសនៃអង្គការឯកជន(២)	:	៣៩.៣៩១ លានរៀល
សរុបចំណាយ	:	៦៦.១៩១ លានរៀល
• ចំណាយជាប្រចាំ	:	៣៩.៣៩១ លានរៀល
• ចំណាយជាមូលធន	:	២៦.៨០០ លានរៀល

(២) ត្រូវបានយល់ព្រមដោយច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ១៩៩៤ រួចហើយ និងត្រូវបានបញ្ជាក់ដោយច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ នៅក្នុងក្របខ័ណ្ឌនៃប្រាក់ខ្ចីពីឯកជនបរទេស ។

ជំពូកទី៤

បទប្បញ្ញត្តិស្តីពីវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិ

មាត្រា៨.- វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ក្រៅរតនាគារជាតិដែលបានគ្រោងចំណូលចំណាយនៅក្នុងច្បាប់ ស្តីពីការកែតំរូវនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ មានចំនួន ទឹកប្រាក់សរុប : ៣៧២.១០០ លានរៀល

• ត្រូវបានអនុវត្តមានចំនួនទឹកប្រាក់	:	៤៥៤.២១៩ លានរៀល
• ដូច្នេះមានចំនួនលើស	:	៨២.១១៩ លានរៀល

ជំពូកទី៥

អវសានប្បញ្ញត្តិ

មាត្រា៩ .- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១	នាយករដ្ឋមន្ត្រីទី២
ព្រះហស្តលេខា	ហត្ថលេខា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការនីតិ
សម្បទានិងអភិវឌ្ឍន៍និងជារដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

* * *

ព្រះរាជក្រម នស/រកម/០២៩៧/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ទ្វតតោសុជាត ទិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ ឯកនរោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅច្បងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២